# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ អភិបូជាបុណ្យព្រះជាម្ចាស់លើកព្រះយេស៊ូ ឡើងស្ថានបរមសុខនៅព្រះសហគមន៍សន្តិម៉ារីញញឹម
# ចំការទៀង ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២០

## ស្គាល់ព្រះយេស៊ូនៅក្នុងការតស៊ូ

**អត្ថបទទី១៖ កិច្ចការ ១,១២-១៤**

ពួកគេរួមចិត្តគំនិតគ្នា ព្យាយាមអធិស្ឋាន។ កក ១,១៤

**អត្ថបទទី២៖ ពេត្រុសទី១ ៤,១៣-១៦**

ប្រសិនបើមានគេត្មះតិះដៀលបងប្អូន ព្រោះតែព្រះនាមរបស់ព្រះគ្រិស្ត* នោះបងប្អូនមានសុភមង្គលហើយ ដ្បិតព្រះវិញ្ញាណប្រកបដោយសិរីរុងរឿង គឺព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ស្ថិតនៅលើបងប្អូន។ ១ពត្រ ៤,១៤

**ដំណឹងល្អ៖ យ៉ូហាន ១៧,១-១១**

បពិត្រព្រះបិតា ឥឡូវនេះដល់ពេលកំណត់ហើយ សូមសម្តែងសិរីរុងរឿងរបស់បុត្រឡើង ដើម្បីឲ្យបុត្រសម្តែងសិរីរុងរឿងរបស់ព្រះបិតាដែរ។ យហ ១៧,១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងថ្វាយអភិបូជាដើម្បីនឹករលឹកព្រះយេស៊ូឡើងស្ថានបរមសុខ អស់រយៈពេល ៤០ថ្ងៃព្រះយេស៊ូបានធ្វើដំណើរជាមួយក្រុមគ្រីស្តទូត បានបង្ហាញសញ្ញាសម្គាល់នីមួយៗដើម្បីឲ្យក្រុមគ្រីស្តទូតយល់ថា ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញពិតមែន។ ថ្ងៃនេះយើងឃើញ ព្រះយេស៊ូឡើងស្ថានបរមសុខ ប៉ុន្តែព្រះអង្គបានអញ្ជើញយើង "**ឲ្យយើងទៅប្រកាសដំណឹងល្អ ដោយធ្វើពិធីជ្រមុជទឹកឲ្យគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ បង្រៀនគេឲ្យប្រតិបត្តតាមសេចក្តីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់ឲ្យ ដោយដឹងថាខ្ញុំនៅជាមួយអ្នករាល់គ្នា**"។

នៅក្នុងពិភពលោកថ្ងៃនេះ យើងដឹងថាយើងកំពុងអធិដ្ឋានតាមផ្ទះ តាមព្រះវិហារ តាមកន្លែងនីមួយៗបាន ដោយសារក្រុមគ្រីស្តទូតទាំង១១នាក់ដែលបានជួបព្រះយេស៊ូ នៅពេលព្រះអង្គឡើងស្ថានបរមសុខ។ គេបានអនុវត្តព្រះបន្ទូលរបស់ព្រះយេស៊ូ ដូចជាធ្វើពិធីជ្រមុជទឹក ទៅដល់តំបន់ដាច់ស្រយាលនៃផែនដី បង្រៀនគេឲ្យធ្វើតាមបង្គាប់ដែលខ្ញុំបានបញ្ជាក់គឺ "**ស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នា**" និងដោយដឹងថាព្រះយេស៊ូគង់នៅជានិច្ច ជាពិសេសតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ ថ្ងៃនេះ ព្រះសហគមន៍ទូទាំងពិភពលោក ជាថ្ងៃដែលយើងគោរពខួបទី៥៤នៃទិវាផ្សព្វផ្សាយព័ត៌មានកាតូលិក។ ៥៤ឆ្នាំមុន ឥតមានការផ្សព្វផ្សាយដូចសព្វថ្ងៃ ឥតមានទូរស័ព្ទដៃ ឥតមានអ៊ិនធើណេត ប្រហែលមានតែទូរស័ព្ទលើតុ មានទូរទស្សន៍សខ្មៅ មានតែវិទ្យុដើម្បីផ្សព្វផ្សាយព័ត៌មានខ្លះៗ ប៉ុន្តែមិនអាចផ្សព្វផ្សាយទៅដល់ពិភពលោកបាន

ទេ។ សព្វថ្ងៃ យើងឃើញរបៀបដែលយើងផ្សព្វផ្សាយស្រួលណាស់ ប៉ុន្តែបើយើងត្រឡប់ដល់ឆ្នាំ ៣០ ដែលក្រុមគ្រីស្តទូតខិតខំផ្សព្វផ្សាយដំណឹងល្អ នៅពេលនោះទូរស័ព្ទក៏គ្មាន វិទ្យុក៏គ្មាន ទូរទស្សន៍ក៏គ្មាន អ៊ិនធើណេតក៏គ្មាន តែគេអាចធ្វើបាន។ ប្រហែលមិនស្រួលនៅក្នុងបរិយាកាស និងកាលៈទេសៈ ដោយសារពេលយើងស្តាប់រឿងក្រុមគ្រីស្តទូតដែលយើងអានរាល់ថ្ងៃមានបញ្ហាច្រើន។ ពេលគេធ្វើដំណើរពីទីក្រុងយេរូសាឡឹម ទៅដល់អន់ទីយ៉ូប ទៅដល់អាទែន ទៅដល់រ៉ូម សុទ្ធតែបានទទួលការបៀតបៀន រហូតដល់គេកាត់កលោកប៉ូល ឆ្កាងលោកសិលាបញ្ច្រាស។ នេះជាការពិបាក ប៉ុន្តែស្រួលនៅក្នុងរបៀបប្រមូលមនុស្ស ពីកន្លែងមួយទៅកន្លែងមួយដូចជានៅធម្មសាលា នៅកន្លែងដែលគេគោរពព្រះដែលមិនស្គាល់នៅទីក្រុងអាទែន ទៅកន្លែងដែលមានផ្ទះគ្រីស្តបរិស័ទ។ មុនដំបូងគេប្រមូលជនជាតិយូដា ក្រោយមកគេចាប់ផ្តើមប្រមូលសាសន៍ដទៃឲ្យគេស្តាប់អំពីជីវិតរបស់ព្រះយេស៊ូ អំពីព្រះជន្មរបស់ព្រះយេស៊ូលើផែនដីនេះ។ ព្រះយេស៊ូបានប្រសូតនៅភូមិបេថ្លេហិម ព្រះយេស៊ូបានរស់នៅភូមិណាសារ៉ែត ក្រោយមកព្រះយេស៊ូចាប់ផ្តើមចេញធ្វើដំណើរ ត្រាស់ហៅក្រុមគ្រីស្តទូត ចាប់ផ្តើមប្រកាសដំណឹងល្អ ណែនាំឲ្យអ្នកក្រីក្រមានសេចក្តីសង្ឃឹម អ្នកជំងឺបានជាសះស្បើយ អ្នកដែលពោរពេញដោយអំពើបាបមានជីវិតថ្មី។ ដូច្នេះពេលសាសន៍ដទៃស្តាប់អំពីរឿងព្រះយេស៊ូគេសប្បាយចិត្ត មួយកន្លែងៗមាន២០០០នាក់ ៥០០០នាក់...។ គេសុខចិត្តដើរតាមព្រះយេស៊ូ គេបានទទួលដំណឹងល្អផ្ទាល់មាត់ នេះណែនាំឲ្យយើងគិតពិចារណាសព្វថ្ងៃ**តើយើងផ្សព្វផ្សាយដំណឹងល្អ តាមរយៈមធ្យោបាយព័ត៌មាននានាដូចម្តេច?**

យើងមានបទពិសោធពិសេសនៅក្នុងរដូវកូវីដ១៩ ដោយសារយើងបានប្រើមធ្យោបាយទំនើបៗដើម្បីផ្សាយអភិបូជា ដើម្បីផ្សាយអធិដ្ឋាន ដើម្បីផ្សាយព័ត៌មាននានា។ នៅរាត្រីបុណ្យចម្លងយើងមានជាង២០០០០នាក់ បានចូលមើលការផ្សាយផ្ទាល់តាមហ្វេសបុក ពេលយើងឡើងភ្នំបូកគោ ដើម្បីធ្វើពិធីប្រសិទ្ធីពរពិសេសសម្រាប់ការត្រាស់ហៅ យើងក៏មានជាង២០០០០នាក់បានចូលមើល។ សព្វថ្ងៃ អ្នកដែលបានចូលមើលការផ្សាយផ្ទាល់ចាប់ផ្តើមថយចុះ យើងអាចមើលព័ត៌មានជាក់ស្តែងអំពីអ្នកដែលបានចូលមើល អ្នកមើលយូរ អ្នកមើលខ្លី អ្នកចុចចូលចិត្ត អ្នកឲ្យយល់បល់ថាល្អ...។ នៅក្នុងអភិបូជាដែលយើងផ្សាយជាង១ម៉ោង គេមើលតែ១នាទី នៅក្នុងព័ត៌មានផ្សេងៗ១០នាទី គេមើលតែ៥០វិនាទី...។ មធ្យោបាយយើងមានច្រើន ប៉ុន្តែខ្ញុំគិតថាមិនទៅដល់បងប្អូន ផ្ទុយទៅវិញពេលលោកប៉ូលអង្គុយជាមួយប្រជាជនគេបានស្តាប់គាត់យូរ ពេលព្រះយេស៊ូបានទៅទេសនាដល់ប្រជាជនជូនកាល២ថ្ងៃគេនៅតែស្តាប់។ ពិភពលោករបស់យើងសព្វថ្ងៃ ដែលមានមធ្យោបាយស្រួលតែមានព័ត៌មានច្រើនណាស់ ក្រោយមកយើងលែងមើលដែលធ្វើ

ឲ្យការផ្សព្វផ្សាយព័ត៌មានរបៀបទំនើបនេះ ណែនាំឲ្យយើងភ្លេចព័ត៌មានដែលយើងចង់ចែករំលែក ដំណឹងល្អដែលយើងចង់ចែករំលែក។

ថ្ងៃនេះ ខ្ញុំសូមសរុបសេចក្តីនៃសារលិខិតរបស់សម្តេចប៉ាប ក្នុងឱកាសទិវាទី៥៥នៃការផ្សព្វផ្សាយព័ត៌មានកាតូលិក ព្រះអង្គបានរំលឹកអំពីជីវិតរបស់យើង អ្វីដែលមនុស្សយើងត្រូវតែធ្វើគឺ៖

- ✓ និទានអំពីជីវិតផ្ទាល់ខ្លួន
- ✓ ស្តាប់បងប្អូនឯទៀតៗនិទានអំពីជីវិតរបស់គេផ្ទាល់
- ✓ ស្តាប់ព្រះយេស៊ូដែលនិទានអំពីជីវិតរបស់ព្រះជាម្ចាស់ឲ្យយើងស្គាល់។

អត្ថបទគម្ពីរ ដែលព្រះសហគមន៍យើងបានចែកដល់ក្រុមគ្រីស្តទូត ខ្ញុំបាននិយាយថាសូមកុំអាន តែនិទានដោយនិយាយអំពីជីវិតរបស់ព្រះយេស៊ូឲ្យគេចាប់អារម្មណ៍ ឲ្យគេស្តាប់។ ពីសម័យដើម គ្មានគម្ពីរទេតែគេបាននិទានអំពីអ្វីដែលគេមានបទពិសោធន៍ជាមួយព្រះយេស៊ូ។ ប្រសិនបើ លោកគ្រូជៀងគាត់និទានអំពីជីវិតរបស់គាត់ជាជនជាតិខ្មែរម្នាក់ ដែលកែប្រែចិត្តគំនិតល្អស្តាប់ណាស់ហើយជាកម្លាំងមួយសម្រាប់យើងទាំងអស់គ្នា។ ពេលលោកឪពុក សុន ត្រឡប់មកពីប្រទេសកាណាដាវិញ បានទៅជួបជាមួយលោកគ្រូជៀង ដោយសារសួរថា **តើធ្លាប់ស្គាល់ព្រះយេស៊ូឬទេ?** លោកគ្រូជៀងថាមិនដែលស្គាល់ទេ។ **តើចាប់អារម្មណ៍ឬអត់?** គាត់ថាចង់ទៅស្តាប់ម្តង ដោយបានចាប់ផ្តើមធ្វើដំណើរពីចំការទៀងទៅផ្សារតូច ជារៀងរាល់អាទិត្យរយៈពេល៥ឆ្នាំដែលបានតស៊ូ។ នេះជាការធ្វើដំណើរជាមួយព្រះយេស៊ូ ដើម្បីស្គាល់ព្រះយេស៊ូនៅក្នុងការតស៊ូនៅឆ្នាំ១៩៩៨ លោកគ្រូជៀងបានទទួលអគ្គសញ្ញាជ្រមុជទឹកនៅផ្សារតូច ពីលោកអភិបាលអេមីល។ ក្រោយមក គាត់បានប្រមូលយុវជនខ្លះៗនៅក្នុងផ្ទះ ដើម្បីស្តាប់គម្ពីរ ដើម្បីនិទានអំពីជីវិតផ្ទាល់ខ្លួន ដើម្បីនិទានអំពីជីវិតរបស់ព្រះយេស៊ូ។ រហូតដល់ឆ្នាំ២០០៣ យើងមានពិធីជ្រមុជទឹកដំបូងនៅទីនេះជាង២០នាក់ បន្តិចម្តងៗរហូតដល់សព្វថ្ងៃយើងមាន៣២២នាក់ ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកនៅទីនេះ។

ចេញពីព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀងនេះ យើងបានបង្កើត៧ព្រះសហគមន៍នៅក្នុងខេត្តតាកែវ និងមានមួយកន្លែងនៅកោះស្លាខេត្តកំពត។ នេះជាការនិទានជីវិតរបស់លោកគ្រូជៀង ដែលណែនាំឲ្យគាត់ទៅជាបិតានៃព្រះសហគមន៍។ អំពីជីវិតខ្ញុំនៅចំការទៀង ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០២ ខ្ញុំបានជួបជាមួយលោកគ្រូជៀងនៅមន្ទីរពេទ្យភ្នែកតាកែវ ដើម្បីជួបជាមួយប្រធានមន្ទីរធម្មការ និងសាសនា ខេត្តតាកែវនៅទីនោះ។ នៅថ្ងៃនោះ ខ្ញុំបានដួលម៉ូតូនៅតាមផ្លូវ

ធ្វើឲ្យយើងមិនបាននិយាយជាមួយប្រធានមន្ទីរ បែរជាទៅលាងរបួសខ្ញុំទៅវិញ។ យប់ខ្ញុំដេកនៅផ្ទះលោកគ្រូជៀង ព្រឹកឡើងទៅកំពតដើម្បីជួលផ្ទះជាមួយលោកឪពុកលី។ បន្តិចម្តងៗ ព្រះសហគមន៍បានរីកចម្រើនជាមួយគ្នា យើងអាចនិទានអំពីការបង្កើតសាលាមត្តេយ្យ សាលាសន្តប្រាំង ស្វ៊ូរ...។ បន្តិចម្តងៗ យើងសរសេរប្រវត្តិសាស្ត្រព្រះសហគមន៍ខ្មែរ យើងមិនសរសេរដោយផ្ញើសារ ឬរូបថតតែប៉ុណ្ណឹង យើងសរសេរដោយនិទាន ដោយជួបគ្នាផ្ទាល់។

សព្វថ្ងៃ ក្រុមគ្រីស្តទូតដែលបានទៅជួបបួនប្រាំនាក់តាមផ្ទះ សំខាន់ជាងយើងបង្ហោះវីដេអូមួយ រូបថតមួយ ដោយសារនៅពេលហ្នឹងយើងបានជួបគេផ្ទាល់ ដើម្បីស្តាប់រឿងគេ ជីវិតគេ។ ពេលយើងជួបគ្នាផ្ទាល់ ដើម្បីនិទានជីវិតរបស់យើងរៀងៗខ្លួន នៅពេលនោះយើងអាចសួរសុខទុក្ខនិងលើកទឹកចិត្តគ្នាទៅវិញទៅមក ។ នៅពេលយើងជួបមុខគ្នា អ្វីដែលយើងខឹងគេ អន់ចិត្តនឹងគេ រិះគន់គេ... តាមបណ្តាញសង្គមលែងចេញអស់ហើយ។ ដោយសារ ពេលយើងជួបគ្នាពីនាក់ជាមួយមនុស្សដែលអន់ចិត្តគ្នា ណែនាំឲ្យយើងយល់ថាយើងគិតខុស យើងអាចសម្រុះសម្រួលគ្នាបាន។ ពេលយើងខឹងអ្នកណាម្នាក់ យើងកុំផ្ញើសារស្តីឲ្យគេ ព្រោះថាដោយសារកំហឹងរបស់យើងណែនាំឲ្យយើងសរសេរតែក្រោយមកយើងស្តាយក្រោយ។ ពេលយើងខឹង យើងនៅស្ងៀមស្ងាត់យើងទៅហាត់ប្រាណ ពេលយើងបាត់ខឹងហើយយើងអាចទៅមុខជាមួយគេបាន។

ចុងក្រោយបំផុត ឲ្យយើងនិទានអំពីជីវិតរបស់ព្រះយេស៊ូ ដោយសារព្រះយេស៊ូចាប់កំណើតជាមនុស្ស ដើម្បីធ្វើដំណើរជាមួយប្រជាជនអ៊ីស្រាអែល។ ព្រះជាម្ចាស់ មិនមែនជាទស្សនៈមួយនៅស្ថានបរមសុខ ដែលយើងស្តាប់ទូទៅ ព្រះយេស៊ូបានធ្វើដំណើរជាមួយគេ ព្រះយេស៊ូបានតស៊ូជាមួយគេ ព្រះយេស៊ូបានរងទុក្ខលំបាករហូតដល់សោយទិវង្គតសម្រាប់យើង។ ព្រះយេស៊ូបានស្តាប់រឿងគេ ស្គាល់គេ ឈ្វេងយល់គេ ដូច្នេះពេលយើងស្តាប់រឿងព្រះយេស៊ូ យើងអាចនិទានរឿងព្រះយេស៊ូដែលសព្វថ្ងៃព្រះអង្គគង់នៅជាមួយយើង។ សព្វថ្ងៃ ព្រះយេស៊ូកំពុងចូលនៅក្នុងជីវិតយើង កំពុងសួរសុខទុក្ខយើង ជីវិតរបស់ព្រះយេស៊ូនៅក្នុងគម្ពីរដំណឹងល្អបំភ្លឺជីវិតរបស់យើង ដើម្បីឲ្យយើងទៅមុខ ដើម្បីឲ្យយើងសម្រេចចិត្តអ្វីដែលត្រឹមត្រូវ អ្វីដែលមិនត្រឹមត្រូវនៅក្នុងជីវិតរបស់យើង។

យើងអរព្រះគុណព្រះជាម្ចាស់ ដែលបានលើកព្រះយេស៊ូឡើងស្ថានបរមសុខ ដោយសារយើងទន្ទឹងរង់ចាំព្រះវិញ្ញាណដ៏វិសុទ្ធយាងមក។ ព្រះវិញ្ញាណដ៏វិសុទ្ធ ជាកម្លាំង ជាប្រាជ្ញាឈ្លាសវៃជាសេចក្តីពិត ជាសេចក្តីស្រឡាញ់ ដែលណែនាំឲ្យយើងកសាងព្រះសហគមន៍របស់យើងបាន។ នៅពេលលោកឪពុកទេសនា យើងរៀបចំយ៉ាងត្រឹមត្រូវ យកចិត្តទុកដាក់រៀបចំ ពេលយើងទេសនាដល់មីង ដល់ពូ ដល់តា ដល់យាយ ដល់យុវជន យើងធ្វើដូចម្តេចដើម្បីឲ្យសម្លេងរបស់

យើងប៉ះចិត្តរបស់គេ និងណែនាំឲ្យគេយកដើម្បីដឹកនាំជីវិតរបស់គេ។ យើងបន្តប្រកាសដំណឹងល្អ ដើម្បីរកមធ្យោបាយថ្មីៗ ដើម្បីជួបជាមួយបងប្អូន កុំឲ្យព្រះសហាគមន៍របស់យើងជាព្រះសហាគមន៍ចាស់ទៅៗ កុំឲ្យព្រះសហាគមន៍របស់យើងប្រមូលតែចាស់ៗតាមកន្លែងនីមួយៗ ធ្វើឲ្យយើងភ្លេចនឹកឃើញយើងមានយុវជន យើងមានកូនក្មេង យើងមានគ្រួសារ។ យើងប្រកាសដំណឹងល្អដល់មនុស្សទាំងអស់គ្រប់អាយុ ដូច្នេះយើងត្រូវការយកចិត្តទុកដាក់ ដើម្បីឲ្យព្រះសហាគមន៍របស់យើងមានជីវិត ដោយសារព្រះយេស៊ូជាជីវិត និងព្រះវិញ្ញាណដ៏វិសុទ្ធដែលយាងមក គឺជីវិតរបស់ព្រះអង្គដែលណែនាំឲ្យយើងទៅមុខ ដើម្បីប្រកាសដំណឹងល្អ និងធ្វើពិធីជ្រមុជទឹកដោយនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ អាម៉ែន៕